សហគមន៍ជនជាតិភាគតិចនៅតែរងផ្លូវពីផលប៉ះពាល់នៃការកសាងទំនប់វារីអគ្គិសនីនៅប្រទេសជិតខាង

ទំនប់វារីអគ្គិសនីយ៉ាលី របស់ភ្លាមណាម (រូបថត Website)

បងប្អូនជនជាតិភាគតិចជួបជុំគ្នារៀបរាប់ពីផលប៉ះពាល់ របស់ទំនប់វារីអគ្គិសនី (រូបថត:ន៣ក)

គាំងតែតាមរយៈការណ៍ផ្សាយ ផលប៉ះពាល់ពីទំនប់វារីអគ្គិសនីនៅក្នុងប្រទេសជិតខាងជាបន្តបន្ទាប់ចាប់ពីពាក់កណ្តាលនៃទសវត្សរ៍ឆ្នាំ១៩៩០ រហូតមកដល់សព្វថ្ងៃនេះ បងប្អូនសហគមន៍ជនជាតិភាគតិចនៅតែបន្តភ្ជាប់ភ្នែកអំពីផលប៉ះពាល់មកលើជីវភាពរបស់ពួកគេ ហើយនៅតែប្តេជ្ញាចិត្តរួបរួមគ្នាជំរុញការតស៊ូមតិបន្តទៀតរហូតដល់មានដំណោះស្រាយសមស្របដល់ពួកគេ ។

យោងទៅតាមរបាយការណ៍ របស់ The NGO Forum on Cambodia បានឱ្យដឹងថា ផលប៉ះពាល់នៃការសាងសង់ទំនប់វារីអគ្គិសនីមកលើបងប្អូនសហគមន៍ជនជាតិភាគតិចដែលរស់នៅតាមដងទន្លេសេសាន សេកុង និងស្រែពក គឺបានចាប់ផ្តើមជាបន្តបន្ទាប់ ចាប់តាំងតែពីឆ្នាំ១៩៩៦មកម្ល៉ះ ។ អង្គការនេះបានរកឃើញថា ចាប់តាំងពីឆ្នាំ១៩៩៦ ស្ថានភាពបរិស្ថាននៅតាមដងទន្លេទាំងបីមានការប្រែប្រួលដូចជា ទឹកឡើង ស្រក និងបាក់ដីខុសពីប្រក្រតី ប៉ុន្តែគេមិនបានដឹងអំពីមូលហេតុ ។ ប៉ុន្តែក្រោយពីអ្នកបរិស្ថានបានចាប់ផ្តើមធ្វើការសិក្សាស្រាវជ្រាវគេក៏បានរកឃើញថា បម្រែបម្រួលបរិស្ថាននៅតាមទន្លេទាំងបីនេះ គឺកើតមានឡើងដោយសារតែការសាងសង់ទំនប់វារីអគ្គិសនីនៅតាមប្រភពខាងលើនៃទន្លេទាំងបី ជាហេតុធ្វើឱ្យសហគមន៍ជនជាតិភាគតិចបានដឹងពីមូលហេតុ ហើយក៏បានរៀបចំចងក្រងគ្នាជាសហគមន៍ក្រោមការសម្របសម្រួលរបស់បណ្តាអង្គការក្រៅរដ្ឋាភិបាលនៅក្នុងស្រុក និងអន្តរជាតិ ដើម្បីធ្វើការតស៊ូមតិ សំដៅធ្វើយ៉ាងណាឱ្យព្យាយាមការពារនូវនិរន្តរភាពបរិស្ថាននៅតាមសហគមន៍របស់ពួកគេ ។

ទន្លេសេសាន សេកុង និងស្រែពក គឺជាទន្លេបីដ៏សំខាន់ ដែលហូរកាត់ខេត្តបីនៅភូមិភាគឈ្មោះនៃប្រទេសកម្ពុជា គឺខេត្តមណ្ឌលគិរី រតនគិរី និងខេត្តស្ទឹងត្រែង ទ៉ាន់ៈគឺជាប្រភពទឹក និងជាប្រភពនៃប្រាក់ចំណូល និងជីវភាពរស់នៅរបស់សហគមន៍ជនជាតិភាគតិចជាច្រើន ដែលមានដូចជា កាចក ឡាវ ចំពូន ការ៉ែត ព្រៅ លន់ ខិះ ត្រឹងជាដើម ។ បណ្តាសហគមន៍ជនជាតិទាំងអស់នោះ តែងតែជួបប្រជុំគ្នាជាប្រចាំនៅក្នុងមួយឆ្នាំមួយដង ដើម្បីប្រាស្រ័ព្ធនូវទន្ទេទាំងបីចាប់តាំងពីឆ្នាំ២០០២មក ដើម្បីសម្តែងពីមតិរបស់ពួកគេចំពោះផលប៉ះពាល់ដល់បរិស្ថានរស់នៅរបស់ពួកគេ ។

ម៉ីក ម៉ាច ជនជាតិព្រៅរស់នៅភូមិប់គេង ឃុំកោះប៉ុង បានឱ្យដឹងថា «ថ្ងៃទី១៥ខែមិថុនាកន្លងទៅនេះ គឺជាថ្ងៃដែលយើងបានជួបគ្នា ដើម្បីសម្តែងមតិរបស់ពួកយើងជុំវិញបញ្ហាបរិស្ថាននៃទន្ទេទាំងបី ។

អ៊ីប្រុស ក្រាំង ហ៊ីម ជនជាតិការ៉ែត រស់នៅភូមិប៉ាកហាយ ឃុំកោះប៉ុង ស្រុកវ៉ឿនសៃ បានឱ្យដឹងថា«យើងរីករាយណាស់ដោយសារមួយឆ្នាំយើងមានពេលជួបគ្នាម្តង ដើម្បីសុំមានការដោះស្រាយអំពីផលប៉ះពាល់ដល់ជីវភាពរស់នៅរបស់យើង» ។

រហូតមកដល់ពេលបច្ចុប្បន្ន នេះផលប៉ះពាល់រួមនៃបណ្តាសហគមន៍ជនជាតិភាគតិចដែលរស់នៅតាមដងទន្ទេទាំងបីនោះ គឺភាគច្រើនបណ្តាលមកពីការកសាងទំនប់វារីអគ្គិសនីនៅផ្នែកខាងលើនៃប្រភពទន្ទេទាំងបី ជាពិសេសគឺទំនប់វារីអគ្គិសនីនៅវៀតណាម



ទន្ទេ៣ស្រាពក ដែលជ្រាបជោរ ជ្រុងនាទ ដោយសារឥទ្ធិពលវារីអគ្គិសនីនៅប្រទេសវៀតណាម (រូបថត:ស្រីនាថ)

គឺទំនប់យ៉ាលី ដែលមានកម្លាំងផលិតថាមពលវ៉ាត២០មេហ្គាវ៉ាត់ ។ ក្រៅពីទំនប់មួយនេះ រដ្ឋាភិបាលឡាវ និងវៀតណាម ក៏កំពុងតែដំណើរការសាងសង់ និងរៀបចំចាប់ផ្តើមសាងសង់នូវទំនប់វារីអគ្គិសនីជាច្រើនទៀតដូចជា សេសានប៊ីអសេសានបួន ទំនប់វារីអគ្គិសនីសេកាម៉ានជាដើម ។

យោងទៅតាមការសិក្សាមួយរបស់អង្គការវេទិការនៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា(NGO Forum on Cambodia) ដែលជាអង្គការក្រៅរដ្ឋាភិបាលមួយកំពុងតែធ្វើការលើគម្រោងតស៊ូមតិជាច្រើនសម្រាប់ជួយដល់ប្រជាពលរដ្ឋនៅក្នុងប្រទេសកម្ពុជាបានឱ្យដឹងថា ដោយសារតែការសាងសង់ទំនប់វារីអគ្គិសនីនៅផ្នែកខាងលើទន្ទេទាំងនេះ របបទឹកនិងនិរន្តរភាពបរិស្ថាននៅតាមទន្ទេទាំងបី គឺសេសាន ស្រែពក និងសេកុង ពិតជាមានការប្រែប្រួលមែន។

របាយការណ៍ដែលការប្រមូលទិន្នន័យតាមរយៈការចុះទៅសម្ភាសន៍ប្រជាពលរដ្ឋដោយផ្ទាល់ និងវិភាគតាមឯកសារយោងមួយចំនួនបានឱ្យដឹងថា ជាទូទៅតំបន់ប្រព័ន្ធអេកូឡូស៊ីនៅតាមទន្ទេទាំងបីនេះ មានលក្ខណៈងាយស្រួលនឹងបំផ្លិចបំផ្លាញណាស់ ដោយសារតែអតិបាលកិច្ចលើធនធានធម្មជាតិហាក់ដូចជាមានលក្ខណៈខ្សោយពេក ។

លោកម៉ាម គេន តំណាងសហគមន៍តាមដងទន្ទេសេសានបានឱ្យដឹងពីផលប៉ះពាល់ថា កន្លងមកក្រោយពីមានការសាងសង់វារីអគ្គិសនីមានផលប៉ះពាល់ជាច្រើនដូចជាទឹកជន់ក្នុងមួយកើតឡើង២ទៅ៣ដង ធ្វើឱ្យលិចផលដំណាំរបស់យើងអស់ជាច្រើន ហើយមានពេលខ្លះបានធ្វើឱ្យដាច់គោក្របីរបស់យើងដែរ។ ក្រៅពីនោះគុណភាពទឹកក៏ប្រែប្រួល ។ ពីមុនយើងអាចប្រើប្រាស់ទឹកបាន ប៉ុន្តែក្រោយពីមានការសាងសង់វារីអគ្គិសនីនេះឡើង ទឹកនោះមិនអាចប្រើប្រាស់បានសម្រាប់ជីវភាពប្រចាំថ្ងៃ ហើយប្រសិនជាងូតវិញធ្វើឱ្យមាស់ចេញកន្ទួលៗដែរ ។ ទៅវិញនោះ ។

ដោយមើលឃើញពីផលប៉ះពាល់នោះ លោកម៉ាម គេន បានសំណូមពរដល់រដ្ឋាភិបាលកម្ពុជានិងប្រទេសវៀតណាម ត្រូវធ្វើការពិចារណាឱ្យបាត់ម៉ត់ចត់ពាក់ព័ន្ធគម្រោងអភិវឌ្ឍន៍នានា ដែលសាងសង់នៅតាមដងទន្ទេទាំងបី សូមឱ្យមានការសិក្សាពីផលប៉ះពាល់បរិស្ថាន សេដ្ឋកិច្ច និងសង្គមដោយមានការចូលរួមនិងសម្រេចចិត្តជាសាធារណៈពីប្រជាពលរដ្ឋជាមុនសិន ហើយសូមម្ចាស់ជំនួយពិចារណាលើការផ្តល់ជំនួយសម្រាប់ផែនការសាងសង់ទំនប់វារីអគ្គិសនី ប្រសិនបើជាគ្មានដំណើរការអតិបាលកិច្ចល្អទៅលើសង្គមនិងបរិស្ថាន ពិសេសប្រជាពលរដ្ឋដែលរស់នៅតាមដងទន្ទេនោះ ។ ជាមួយគ្នានោះ ស្នើសុំឱ្យរដ្ឋាភិបាលក្នុងតំបន់មេគង្គទាំងអស់ អនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់នូវស្មារតីនៃកិច្ចសហប្រតិបត្តិការដែលបានចែងក្នុងកិច្ចព្រមព្រៀងទន្ទេមេគង្គ ។

អ៊ីស្រ៊ីទ្ធ ដែន រស់នៅភូមិអូរកាន ឃុំជ័យឧត្តម ស្រុកលំផាត់ ខេត្តរតនគិរីតាមដងទន្ទេស្រែពក បានឱ្យដឹងថា ក្រោយពីការសាងសង់ទំនប់វារីអគ្គិសនីទឹកកាវឡើងចុះ មិនទៀងនោះទេ ពេលខ្លះមានទឹកជន់ធ្វើឱ្យខូចខាតដំណាំផ្សេងៗ ពេលខ្លះគ្មានទឹកដោយសារតែការទប់ទឹកពីខាងលើ ។

អ្នកស្រីសិន ថងឡាវ តំណាងសហគមន៍តាមដងទន្ទេស្រែពកបានឱ្យដឹងថា ប្រហាក់ប្រហែលនឹងអ្នកខាងលើដែរ ។

លោកយ្យន ទេងរស់នៅឃុំកោះឤម ស្រុកវ៉ឿនសៃ ខេត្តរតនគិរី បានឱ្យដឹងថា ចាប់តាំងពីគេសាងសង់ទំនប់នោះមក ការបង្កបង្កើនផលមានការថយចុះ ដោយសារតែទឹកវាមិនគ្រប់គ្រាន់ ដល់ពេលបង្កបង្កើនផលបានទឹកជន់លិចអស់មិនបានទទួលផលអ្វីទាំងអស់ ដូច្នេះធ្វើឱ្យជីវភាពរបស់លោកជួបការខ្វះខាត ។ លោកបានបន្តថា ដោយឡែកការនេសាទត្រីក៏មានការថយចុះដែរ មិនស្មើជាសម្បូរដូចកាលពីមិនទាន់មានការសាងសង់ទំនប់នោះទេ ។

អ៊ីស្រ៊ីចន ម៉ាយ រស់នៅភូមិកាចូនក្រោម ឃុំកាចូនក្រោម ស្រុកវ៉ឿនសៃ បានឱ្យដឹងថា រហូតមកដល់ពេលនេះ យើងបានជួបគ្នាជាបន្តបន្ទាប់ ប៉ុន្តែយើងហាក់ដូចជានៅមិនទាន់ទទួលបានសំណងអ្វីដល់ជីវភាពរស់នៅរបស់យើងនៅឡើយ ។

លោកម៉ាម គេនបានឱ្យដឹងថាយើងនឹងបន្តការជួបជុំគ្នានេះ បន្តជារៀងរាល់ឆ្នាំបន្តទៀត ដើម្បីឱ្យសាធារណៈដឹងអំពីផលប៉ះពាល់របស់ពួកយើង ហើយសុំឱ្យអ្នកដែលសាងសង់ទំនប់ពិនិត្យនិងសិក្សាឱ្យបានច្បាស់លាស់នៅមុននឹងសាងសង់អ្វីបន្ថែមទៀត ។

តាមគម្រោងវៀតណាម ថៃ និងរដ្ឋាភិបាលកម្ពុជានៅមានគម្រោងសាងសង់ទំនប់វារីជាច្រើនកន្លែងទៀតបន្ថែមលើទំនប់វារីអគ្គិសនីដែលមានស្រាប់នៅតាមប្រភពខាងលើ និងតាមដងទន្ទេទាំងបី ។

ន៣ក-ពិន្ទារ

ក្រោមកិច្ចសហប្រតិបត្តិការជាមួយអង្គការ The NGO Forum on Cambodia